# តួនាទីអ្នកធ្វើច្បាប់[១៦]



## ក) **គោលការណ៍ចំបងពីរ**

យោងតាមមាត្រា៧៧ CC ចែងថា សមាជិកសភាគឺៈ

- **ជាតំណាងប្រជាពលរដ្ឋកម្ពុជាទាំងមូល** និង
- **មិនជាប់កាតព្វកិច្ចធ្វើតាមការណែនាំ ឬការបង្គាប់បញ្ជាណាមួយឡើយ គឺធ្វើទៅតាមតែមនសិការរបស់ខ្លួន** ដែលជាជំនឿនៃអ្វីដែលបំរើជាតិជាធំ ។

| |
|---|
| មាត្រា៧៧ CC:<br>តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាង**ប្រជាពលរដ្ឋខ្មែរទាំងមូល** ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។<br>**អាណត្តិអាជ្ញាបញ្ជាទាំងឡាយ ត្រូវទុកជាមោឃៈ។** |

ពាក្យថា "**អាណត្តិសេរី**" ដែលមានន័យផ្សេងពីពាក្យថា អាណត្តិអាជ្ញាបញ្ជា ហាមឃាត់អ្នកបោះឆ្នោត ឬ គណបក្ស ឬអង្គការរបស់ខ្លួនក្នុងការផ្តល់សេចក្តីណែនាំដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះតំណាងរាស្ត្រណាម្នាក់ ។ គោលការណ៍នៃអាណត្តិសេរីនេះគឺជាតួអង្គ (embodiment) យ៉ាងសំខាន់ក្នុងគោលការណ៍ប្រជាធិបតេយ្យដោយតំណាងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ( មាត្រា ៥១ CC) ។

[១៦] ពាក្យថា"អ្នកធ្វើច្បាប់" សំដៅទៅលើអ្នកតំណាងរាស្ត្រ នៅក្នុងរដ្ឋសភា ក៏ដូចជានៅក្នុងព្រឹទ្ធសភា

រដ្ឋធម្មនុញ្ញចង់ឱ្យតំណាងរាស្ត្រមានសេរីភាពពីសមាជិកភាពរបស់ខ្លួននៃគណបក្សនយោបាយណាមួយ ។ សេរីភាពនេះអនុញ្ញាតឱ្យគណបក្ស គ្រាន់តែ**អាចធ្វើសំណើ ផ្តល់អនុសាសន៍ ឬសង្ឃឹម**ទៅលើអ្នកតំណាងថា នឹងបញ្ចេញមតិគំនិតរបស់ខ្លួន ឬបោះឆ្នោតតាមមធ្យោបាយជាក់លាក់មួយ ប៉ុន្តែ**មិនតំរូវ** ឬចាប់បង្ខំអ្នកតំណាងឱ្យគោរពតាមខ្សែបន្ទាត់របស់គណបក្សនោះទេ ។

គោលការណ៍អាណត្តិសេរីរួមបញ្ចូល **ការរក្សាអាណត្តិជាអ្នកតំណាងរាស្ត្រក្នុងករណីនៃការចាកចេញ ឬការផ្លាស់ប្តូរគណបក្ស ឬការដែលត្រូវបណ្តេញចេញពីបក្ស** ។ តំណែងនៅសភាមិនមែនជារបស់គណបក្សទេ ប៉ុន្តែវាជារបស់តំណាងរាស្ត្រដែលជាប់ឆ្នោត ។ ទង្វើអាក្រក់របស់តំណាងរាស្ត្រម្នាក់ អាចជាលទ្ធផលអវិជ្ជមានសំរាប់ការបោះឆ្នោតលើកក្រោយ ពេលដែលអ្នកបោះឆ្នោត មិនពេញចិត្តនឹងគណបក្សដែលដាក់ឈ្មោះបេក្ខជនដែលគ្មានសមត្ថភាពនោះ មកដដែល ។

<u>ឧទាហរណ៍</u>ករណីអធម្មនុញ្ញភាពទាំងស្រុងមួយ[១៧] :

នៅខែធ្នូ ឆ្នាំ ២០០១ សមាជិកព្រឹទ្ធសភា ៣រូប (ឆាំង សុង, ផៃ ស៊ីផាន និង ពូ សាវ៉ាត) **<u>ត្រូវបណ្តេញចេញ</u>**ពីគណបក្សរបស់ខ្លួនគឺគណបក្សប្រជាជនកម្ពុជា ពីព្រោះតែ អ្នកទាំងនោះមិនបានគោរពតាមខ្សែបន្ទាត់របស់បក្ស តែបែរជាធ្វើការរិះគន់លើសេចក្តីព្រាងក្រមព្រហ្មទណ្ឌថែមទៀតផង ។ ប្រធានព្រឹទ្ធសភា សម្តេច ជា ស៊ីម **<u>បានបណ្តេញ</u>** អ្នកតំណាងចំនួន៣រូប**<u>ពីព្រឹទ្ធសភា</u>**ដោយគ្មានការជូនដំណឹង ឬ ដោយគ្មាននីតិវិធី និងបានពន្យល់បកស្រាយពីសេចក្តីសំរេចរបស់ខ្លួនដូចតទៅ: "...ទំលាប់អនុវត្តន៍ និងច្បាប់របស់យើង ចែងអំពីការបាត់បង់តំណែងនៅក្នុងព្រឹទ្ធសភា ក្នុងករណីដែលសមាជិកណាម្នាក់ ត្រូវបណ្តេញពីគណបក្សរបស់ខ្លួន... ការបោះឆ្នោតរបស់យើងធ្វើតាមប្រព័ន្ធសមាមាត្រដែលក្នុងនោះ ប្រជាពលរដ្ឋបោះឆ្នោតឱ្យគណបក្ស មិនមែនបោះឆ្នោតឱ្យរូបវ័ន្តបុគ្គលនោះទេ ។ ហេតុដូច្នេះ តំណែងដែលកាន់ដោយសមាជិកជារូបវ័ន្តបុគ្គលនោះ ត្រូវមានទំនាក់ទំនងទៅនឹងសមាជិកភាពនៅក្នុងគណបក្ស ..."

បើក្រឡេកមើលមួយភ្លែតទៅលើរដ្ឋធម្មនុញ្ញ ឬបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាបង្ហាញថា គ្មានបទបញ្ជាបែបនេះទេ ។ ការអនុវត្តន៍ធម្មតា មិនអាចផ្ទុយទៅនឹងគោលការណ៍ធម្មនុញ្ញភាពនៃអាណត្តិសេរីបាននោះទេ ។ ការបណ្តេញចេញនេះគឺជាការបំពានរដ្ឋធម្មនុញ្ញ និងគោលការណ៍ប្រជាធិបតេយ្យដោយតំណាង[១៨] យ៉ាងច្បាស់ ។

## ខ) <u>សិទ្ធិនាំឯឡាយរបស់អ្នកធ្វើច្បាប់:</u>

*ភារកិច្ចចំបងរបស់អ្នកតំណាង ក្រៅអំពីការធ្វើច្បាប់* (មាត្រា៩០ I និង មាត្រា៩១ CC) **គឺត្រួតពិនិត្យមើលសកម្មភាពរបស់រដ្ឋាភិបាល** ។ ដើម្បីធានាថា សកម្មភាពរបស់រដ្ឋាភិបាលមិនស្ថិត នៅក្រៅច្បាប់ និងក្រៅពីផលប្រយោជន៍របស់ប្រជាពលរដ្ឋ អ្នកតំណាងគ្រប់រូបមានសិទ្ធិដូចតទៅ:

[១៧] ព័ត៌មានលំអិតពាក់ព័ន្ធនឹងតួនាទីរបស់តំណាងរាស្ត្រ សូមមើលគេហទំព័រស្តីពី "សហភាពអន្តរសភា (IPU)" ដែលការពារសិទ្ធិរបស់អ្នកតំណាងរាស្ត្រទូទាំងពិភពលោក: www.ipu.org

[១៨] "សហភាពអន្តរសភា" (IPU) បានថែងយ៉ាងច្បាស់នៅក្នុងសេចក្តីសំរេចជាឯកច្ឆ័ន្ទ នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០២ ដោយប្រឆាំងនឹងសេចក្តីសំរេចរបស់ប្រធានព្រឹទ្ធសភាកម្ពុជា — សូមមើល www.ipu.org/hr-e/171/Cmbd18.htm

**I)** សិទ្ធិរួមគ្នា និងបង្កើតជា **ក្រុមសមាជិកសភា** (ក្រុមតូចៗ= fractions) មានន័យថា ដើម្បីអនុវត្តសិទ្ធិក្នុងការបង្កើតសមាគម (មាត្រា៤២ I CC និងមាត្រា២២ ចំនុចទី១ ICCPR) និងដើម្បីឱ្យតែកាន់ខ្លាំង និងកាន់តែទាក់ទាញជាមួយនឹងអ្នកតំណាងដែលមានគំនិតដូចគ្នា ក្នុងការធ្វើសេចក្តីសំរេច ដូចជា:

មុខងារត្រួតពិនិត្យ

- កោះអញ្ជើញសមាជិករដ្ឋាភិបាលណាម្នាក់មកបង្ហាញខ្លួននៅចំពោះមុខរដ្ឋសភា ដើម្បីឆ្លើយសំណួរ
  មាត្រា៨៩ និងមាត្រា៩៧ CC និង ប្រការ៣២ ដល់ ៣៤ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា
- ដាក់ញត្តិប្រឆាំងនឹងរដ្ឋាភិបាល មាត្រា៩៦ I ១ CC
- បណ្តេញសមាជិករដ្ឋាភិបាលណាម្នាក់
  មាត្រា៩៨ CC និង ប្រការ៣៥ នៃ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា
- ចោទប្រកាន់សមាជិករដ្ឋាភិបាលណាម្នាក់ ក្នុងករណីប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ
  មាត្រា១២៦ II III CC ។

ការបង្កើតក្រុមសមាជិកសភា(ក្រុមតូចៗ) គឺកំពុងតែអនុវត្តសិទ្ធិក្នុងការចូលរួមជាសមាគម មាត្រា៤២ I CC និងមាត្រា២២ កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ។

**II)** សិទ្ធិក្នុងការ **ជួបផ្លាស់ប្តូរយោបល់ និងពិភាក្សា** ជាចំហ និងបញ្ចេញមតិដោយគ្មានការភ័យខ្លាច និងតាមមធ្យោបាយច្បាស់លាស់ និងមានការសម្របសម្រួល ដែលថាតំណាងរាស្ត្រគ្រប់រូបអាចចូលរួមចែករំលែកស្មើគ្នានូវការព្រួយបារម្ភ បទពិសោធន៍ និងភាពជំនាញរបស់ខ្លួន (ប្រការ៣៦ នៃ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ។

ការចូលរួមនេះត្រូវអនុវត្តតាមរយះ:

- ការលើកដៃ (ប្រការ៣៧ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ឬបោះឆ្នោតដោយចំហ (ប្រការ៣៩ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ឬ
- ការបោះឆ្នោតដោយ**សម្ងាត់** (ប្រការ៣៨ ដល់ ៤០ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា)

ការបោះឆ្នោត**ដោយបញ្ចេញឈ្មោះ** គួរនៅតែជា**ការលើកលែងដើម្បី**កាត់បន្ថយគ្រោះថ្នាក់ពីឥទ្ធិពលខាងក្រៅទៅលើកាយវិការនៃការបោះឆ្នោតរបស់តំណាងរាស្ត្រ ។ ការបោះឆ្នោតដោយសម្ងាត់ មិនត្រឹមតែប្រើនៅក្នុងករណីដែលមានចែងក្នុងប្រការ៤០ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាប៉ុណ្ណោះទេ (ថែមទាំងការតែងតាំង និងការសំដែងការទុកចិត្ត ។ល។) **ការបោះឆ្នោតជាសម្ងាត់ គួរតែត្រូវបានចែងជាវិធានទូទៅ ។**

## III) សិទ្ធិទទួលបាន **អភ័យឯកសិទ្ធិ** ( មាត្រា៨០ និង ១០៤ CC)



មាត្រា៨០ CC:

តំណាងរាស្ត្រមាន**អភ័យឯកសិទ្ធិសភា** ។

**តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។**

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះ សម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

នៅក្នុងការអនុវត្តនីតួនាទីរបស់ខ្លួនជា "អ្នកឃ្លាំមើល" ដ៏មានប្រសិទ្ធភាពរបស់រដ្ឋាភិបាល ជួនកាលអ្នកតំណាង ធ្វើសេចក្តីថ្លែងការណ៍ដែលគ្មានភស្តុតាងចោទប្រកាន់មន្ត្រីរដ្ឋាភិបាលអំពីការប្រព្រឹត្តខុស ឬដោយគ្មានភាពអំណត់ និងដោយមិនមានការគួរសមក្នុងការស្នើសុំការពន្យល់បកស្រាយពីរដ្ឋាភិបាល ។ នៅស្ថានភាពជាក់ស្តែងគេអាចគិតថា សេចក្តីថ្លែងការណ៍នោះ ជាការបរិហារកេរ្តិ៍ ដែលនេះជាបទល្មើសទាំងផ្នែករដ្ឋប្បវេណី ទាំងព្រហ្មទណ្ឌ ។ បើគ្មានការលើកលែងពីការដាក់ទណ្ឌកម្មទេ អ្នកតំណាងតែងតែប្រឈមមុខនឹងគ្រោះថ្នាក់នៃការចោទប្រកាន់អំពីបទបរិហារកេរ្តិ៍ និងអាចជ្រើសរើសយកការមិននិយាយជាជាងការភ័យខ្លាច ដោយសារតុលាការដាក់ទោស ។

ដើម្បីជៀសវាងការភ័យខ្លាចដូចខាងលើ អភ័យឯកសិទ្ធិសភា ការពារអ្នកតំណាងឱ្យរួចផុតពីការចោទ-ប្រកាន់ ក៏ដូចជាការលើកទឹកចិត្តពួកគេក្នុងការនិយាយស្តីដោយសេរី និងគ្មានការភ័យខ្លាច ។ ធ្វើដូចនេះ វាធានាឱ្យមានការពិភាក្សាមួយដ៏រស់រវើក និងការអនុវត្តនីមួយដែលមានប្រសិទ្ធិភាពនៅក្នុងមុខងារត្រួតពិនិត្យរបស់រដ្ឋសភា ។

អភ័យឯកសិទ្ធិរដ្ឋសភា មានន័យថា តំណាងរាស្ត្រអាចត្រូវទទួលខុសត្រូវចំពោះច្បាប់ព្រហ្មទណ្ឌ ក្នុងករណីតែមួយគត់គឺនៅពេលដែលមានសំលេងគាំទ្រ២/៣ នៃសមាជិករដ្ឋសភាទាំងមូល ។ នៅពេលសភាកោះប្រជុំដើម្បីសំរេចទៅតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬតុលាការ រដ្ឋសភាមិនអនុញ្ញាតឱ្យពិនិត្យវិនិច្ឆ័យទៅលើភស្តុតាងថាតើបទល្មើសព្រហ្មទណ្ឌនោះ (ឧទាហរណ៍ បទបង្ខូចកេរ្តិ៍ឈ្មោះ) ត្រូវបានប្រព្រឹត្ត ឬអត់នោះទេ នោះគឺជាភារកិច្ចរបស់អង្គយុត្តាធិការតែមួយគត់! រដ្ឋសភាគ្រាន់តែ អាចថ្លឹងថ្លែងអំពីផលប្រយោជន៍រវាងម្ខាងជាការបំពេញមុខងារឯករាជ្យរបស់សភា និងម្ខាងទៀតជាអំណាចយុត្តាធិការនៅក្នុងការដាក់ទណ្ឌកម្មលើការបំពានច្បាប់ ។ មានតែ

ត្រូវឆ្លើយសំណួរតទៅនេះទេថា តើអ្វីមានសារៈសំខាន់ជាងនៅក្នុងករណីជាក់ស្តែង? ការរក្សាការប្រព្រឹត្តិទៅរបស់រដ្ឋសភា ឬការផ្តល់លទ្ធភាពឱ្យមានការចោទប្រកាន់អំពីបទល្មើស (ធ្ងន់ធ្ងរ)? ចំលើយអាស្រ័យទៅលើស្ថានទំងន់នៃការបំពានច្បាប់នោះ មានក៏រិតណា ។

គោលការណ៍អភ័យឯកសិទ្ធិ ការពារ ការប្រព្រឹត្តទៅ និងមុខងារ របស់សភា និងធានាលទ្ធភាព (Possibility) ឱ្យមានការពិភាក្សាដោយចំហរ និងដោយសេរីនៅក្នុងសភា ។ នៅក្នុងប្រទេសកាន់លទ្ធិ-ប្រជាធិបតេយ្យដ៏ឧត្តុង្គឧត្តម ការប្រជុំពិភាក្សាដោយផ្ទាល់ក្នុងចំណោមតំណាងរាស្រ្ត គឺមានសារៈសំខាន់ខ្លាំងណាស់ ។ ការប្រជុំ និងការពិភាក្សាអាចនាំមកនូវភាពច្រើនមួយកន្លែងបាន បើអ្នកធ្វើច្បាប់ត្រូវសុំអភ័យទោសបន្ទាប់ពីរាល់ពេលដែលបាននិយាយវាយប្រហារនោះ ពួកគេចាប់ផ្តើម ឬតែងតែភ័យខ្លាចអំពីផលវិបាកតាមផ្លូវច្បាប់ មុនពេលដែលពួកគេផ្តល់យោបល់អ្វីមួយ ។

ជំនួសការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ នៅមានទោសផ្សេងទៀតសម្រាប់ផ្តន្ទាលើការប្រើពាក្យសំដីបំពានអាចជាសំណូមពររបស់ប្រធានរដ្ឋសភា ដើម្បីរក្សាសណ្តាប់ធ្នាប់របស់រដ្ឋសភា (ប្រការ៦២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ។

**IV) សិទ្ធិជា សមាជិកគណៈកម្មាការមួយ** (មាត្រា៨២ I និងមាត្រា៩៤ I CC ជាមួយនឹងប្រការ៦ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ដែលតំណាងរាស្រ្ត អាចនាំយកមកប្រើនូវជំនាញពិសេសរបស់ខ្លួន ។

តំណាងរាស្រ្តគ្រប់រូប អាចជា**សមាជិកនៃគណៈកម្មាការមួយយ៉ាងតិច** ដូច្នេះ ជំនាញរបស់តំណាងរាស្រ្តទាំងអស់ អាចត្រូវប្រើក្នុងដំណើរការធ្វើសេចក្តីសំរេចរបស់សភា ។ គ្មានបទបញ្ញត្តិណាមួយនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ដែលថាសម័យប្រជុំរបស់**គណៈកម្មាការ** ត្រូវធ្វើជាសាធារណៈ ឬអត់នោះទេ ប៉ុន្តែ មាត្រា៨៨ I CC ចែងថា **ជាគោលការណ៍** គ្រប់សម័យប្រជុំសភាត្រូវធ្វើជាសាធាណៈ ។ គោលការណ៍នេះ ត្រូវអនុវត្តន៏ផងដែរ ចំពោះសម័យប្រជុំរបស់**គណៈកម្មាការ** ដើម្បីធានាអំពីធម្មានុភាពនៃដំណើរការធ្វើច្បាប់ ។

**V) សិទ្ធិទទួលបាន មៀវតម្រូវដូចគ្នា នឹងមន្ត្រីរដ្ឋាភិបាល ដែលអ្នកធ្វើច្បាប់ជាអ្នកត្រួតពិនិត្យ** (មាត្រា៨១ II CC ភ្ជាប់នឹង ប្រការ៤ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ។

នេះបង្ហាញថា អំណាចនីតិបទបញ្ញត្តិ មានសារៈសំខាន់ ដូចគ្នានឹងអំណាចនីតិប្រតិបត្តិដែរ ។

**VI) សេចក្តីស្នើដើម្បី ពង្រឹង ដល់អ្នកតាក់តែងច្បាប់កម្ពុជា:**

ដើម្បីធ្វើឱ្យប្រសើរឡើងនូវដំណើរការ និងការប្រព្រឹត្តទៅនៃសភា តំណាងរាស្រ្តអាចគិតពិចារណាទៅលើ**សំណើដូចខាងក្រោម** ដែលឆ្លុះបញ្ចាំងអំពីក៏រិតដំណើរការល្អរបស់រដ្ឋសភា នៃប្រទេសកាន់លទ្ធិប្រជាធិបតេយ្យនៅក្នុងពិភពលោក:

១) តំណាងរាស្រ្ត ត្រូវមាន**សិទ្ធិជាក់លាក់ក្នុងការទទួលបាននូវកំណត់ហេតុ និងឯកសារទាំងឡាយ** របស់រដ្ឋសភា របស់ស្ថាប័នរបស់ខ្លួន និងរបស់រដ្ឋាភិបាលផងដែរ ។ សិទ្ធិនេះជាការចាំបាច់ក្នុងការផ្តល់ឱ្យអ្នកតំណាងនូវមូលដ្ឋានពិតប្រាកដនៃព័ត៌មានដែលពួកគេអាចយកមកបង្កើតសេចក្តីសំរេចរបស់ខ្លួន ។ បើគ្មានព័ត៌មាន ត្រឹមត្រូវក៏គ្មានសេចក្តីសំរេចដែលប្រកបដោយភាពប៉ិនប្រសព្វ ក្នុងរឿងផលប្រយោជន៏របស់ប្រជាពលរដ្ឋខ្មែរដែរ!

**២)** តំណាងរាស្ត្រ ត្រូវទទួលបាន**ការការពារពីការបណ្តេញចេញពីគណបក្សរបស់ខ្លួន** ។ តំណែងរបស់តំណាងរាស្ត្រ ត្រូវទុកឱ្យទំនេររហូតដល់ពួកគេអាចត្រឡប់មកកាន់តំណែងវិញ បន្ទាប់ពី ពួកគេបានបញ្ចប់អាណត្តិរបស់ខ្លួន ។

៣) តំណាងរាស្ត្រ ត្រូវទទួលបានសិទ្ធិមិនត្រូវគេបង្ខំឱ្យបំពានការរក្សាការសំងាត់ និងបិទបាំងពីអត្ត-សញ្ញាណ របស់ប្រជាពលរដ្ឋដែលជាអ្នកប្រាប់ព័ត៌មានសំខាន់ទាក់ទងនឹងនយោបាយ (ដូចជា ព័ត៌មានលំអិតអំពីសកម្មភាពកាប់ឈើ) ។ តំណាងរាស្ត្រ ត្រូវមានសិទ្ធិការពារប្រភពព័ត៌មានដែលខ្លួនទទួលបាន និង**ទទួលបានសិទ្ធិក្នុងការបដិសេធមិនផ្តល់ភស្តុតាង**អំពីឈ្មោះរបស់ពលរដ្ឋដែលខ្លួនបានទទួលពត៌មាននោះ នៅចំពោះមុខតុលាការ ឬអាជ្ញាធរណាមួយនោះទេ ។

៤) តំណាងរាស្ត្រ ត្រូវមានសិទ្ធិទាមទារឱ្យមាន**គណៈកម្មាធិការស្វែងរកការពិត** ។ មានគណៈកម្មការស៊ើបអង្កេតពិសេសត្រូវបានបង្កើតឡើង ដើម្បីបង្ហាញករណីប្រភេទណាមួយនៃការរំលោភអំណាចនៅក្នុងរដ្ឋាភិ-បាល និងក្នុងជួររដ្ឋបាលគ្រប់គ្រង ។ គណៈកម្មាធិការនេះអាចត្រូវបង្កើតឡើង នៅពេលដែលរឿងទាក់ទងនឹងការរំលោភបំពានអំណាច ក្លាយទៅជាបញ្ហាសាធារណៈ ។ គណៈកម្មាធិការនេះ ធ្វើជាអង្គត្រួតពិនិត្យ និងជាប្រភពពត៌មានសំរាប់សភាផងដែរ ។ គណៈកម្មការទាំងនេះ មានអំណាចធ្វើការស៊ើបអង្កេតខ្លាំងប្រហាក់ប្រហែលនឹងអំណាចរបស់ចៅក្រម ឬព្រះរាជអាជ្ញាផងដែរ ។

៥) តំណាងរាស្ត្រត្រូវទទួលបានសិទ្ធិក្នុងការបង្កើត**គណៈកម្មាការសាកសួរព័ត៌មាន** ដែលរៀបចំសេចក្តីសំរេចរបស់សភាទៅលើបញ្ហាស្មុគស្មាញ និងសំខាន់ ដូចជា សេចក្តីសំរេចទាក់ទងនឹងទន្លេមេគង្គ គំរោងច្រាំងទន្លេ ឬការរកឃើញភាពស្មុគស្មាញផ្នែកពាណិជ្ជកម្មក្នុងតំបន់ត្រូវការពារ ។

៦) ដូចមានចែងក្នុង**មាត្រា៩៦ VI ១ CC** រួចហើយថា តំណាងរាស្ត្រ ត្រូវធ្វើជាញឹកញាប់តាមលទ្ធភាពក្នុងការសួរដេញដោលរាជរដ្ឋាភិបាល **នៅពេលមានបញ្ហាបន្ទាន់អំពីផលប្រយោជន៍សាធារណៈដែលបានកើតឡើង** ឧទាហរណ៍ ការចុះហត្ថលេខានាពេលថ្មីនេះលើកិច្ចសន្យាស្តីអំពីព្រំដែនជាមួយនឹងប្រទេសជិតខាង ។

## **គ) ភារកិច្ចរបស់អ្នកធ្វើច្បាប់:**

តំណាងរាស្ត្រ មិនត្រឹមតែទទួលបាននូវសិទ្ធិនោះទេ ថែមទាំងមានភារកិច្ចក្នុងការធានាឱ្យមានការទទួលខុសត្រូវ និងការទុកចិត្តចំពោះប្រជាពលរដ្ឋកម្ពុជាទៀតផង ។

ឧទាហរណ៍ ដំណើរការ និងការប្រព្រឹត្តទៅនៃរដ្ឋសភា អាចធ្លាក់ចុះនៅពេលដែលតំណាងរាស្ត្រគ្រាន់តែមិនមកបង្ហាញខ្លួនក្នុងអំឡុងពេលសម័យប្រជុំសភា ។ ប្រភេទនៃការរាំងស្ទះដល់ការធ្វើសេចក្តីសំរេចនេះ ត្រូវបានគេប្រើជាញឹកញាប់នៅពេលថ្មីៗនេះ ដើម្បីធ្វើមិនឱ្យសភាមិនគ្រប់កូរ៉ុមប្រជុំជាចាំបាច់ចំនួន **៧/១០ នៃតំណាងរាស្ត្រដែលវត្តមាន** ដើម្បីសំរេចលើច្បាប់ណាមួយ (មាត្រា៨៨ II CC) ។

ដើម្បីជៀសវាងបញ្ហានេះ និងឧបសគ្គផ្សេងទៀត សំរាប់ដំណើរការរបស់សភា តំណាងរាស្ត្រគ្រប់រូបត្រូវគោរពតាមភារកិច្ចដូចខាងក្រោម:

**I) ភារកិច្ចក្នុងការចូលរួមទៀងទាត់** ក្នុងសម័យប្រជុំរបស់រដ្ឋសភា ឬសម័យប្រជុំរបស់គណៈកម្មាការសភា (ប្រការ៦៧ និង ១៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ។

តំណាងរាស្ត្រគ្រប់រូប មានសិទ្ធិឈប់សំរាក**១៥ថ្ងៃសំរាប់សម័យប្រជុំនីមួយៗ** (ប្រការ៦៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ។

ប៉ុន្តែ បើតំណាងរាស្ត្រខកខានមិនបានចូលរួមសម័យប្រជុំដោយ**គ្មានមូលហេតុសមស្រប** (ដូចជា មានជំងឺត្រូវមានវេជ្ជបញ្ជាជាភស្តុតាងមកបញ្ជាក់) ទោសវិន័យមានដូចខាងក្រោម (ប្រការ៧២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា)៖

- ព្រមាន បើអវត្តមានចំនួនពីរថ្ងៃ
- កាត់ប្រាក់ឧបត្ថម្ភ ទៅតាមចំនួនថ្ងៃអវត្តមាន
- **បណ្តេញចេញពីសម័យប្រជុំចំនួន១៥ថ្ងៃ**
- **កាត់ប្រាក់ឧបត្ថម្ភ បណ្តេញពីសម័យប្រជុំចំនួន១ខែ និងបិទផ្សាយសាធារណៈនៅមណ្ឌលដែលខ្លួនជាតំណាង ។**

ដើម្បីសំរេចថា មូលហេតុអ្វីជាមូលហេតុសមស្រប និងមិនសមស្រប វាអាស្រ័យទៅលើគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា វាមិនមែនអាស្រ័យលើបុគ្គលតែម្នាក់នោះទេ (ប្រការ៧២ កថាខណ្ឌទី៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ។

**II) ភារកិច្ចក្នុងការគោរពពេលវេលាដែលបានផ្តល់ឱ្យរយៈពេល២០នាទី** ក្នុងការនិយាយ នៅអំឡុងពេលសម័យប្រជុំ (ប្រការ៥៩ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ។



ការកំណត់ក្នុងការនិយាយយ៉ាងតឹងរឹងនេះធានាថា តំណាងរាស្ត្រគ្រប់រូបទទួលបានការយកចិត្តទុកដាក់ដូចគ្នា មិនថាតំណាងរាស្ត្រមកកគណបក្សកាន់អំណាច ឬគណបក្សប្រឆាំងនោះទេ ។

**III) ភារកិច្ចមិនកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ និងមិនមែនជាសមាជិករបស់ស្ថាប័នណាមួយ** ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ (លើកលែងការបំរើការក្នុងជួររាជរដ្ឋាភិបាល មាត្រា៧៩ I CC) និងនៅពេលតែមួយ កាន់តំណែងណាមួយក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការណាមួយ **(វិសមិតភាព)** ។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងការទទួលខុសត្រូវក្នុងដំណើរការធ្វើសេចក្តីសំរេចនៅក្នុងសភាតំណាងរាស្ត្រ អាចឆ្លុះបញ្ចាំងតាមការបង្កើតនូវភារកិច្ចថ្មី ដែលចងកាតព្វកិច្ចខ្លួនទៅនឹង**ការផ្សព្វផ្សាយជាសាធារណៈ អំពីវិជ្ជាជីវៈ តួនាទី និងប្រាក់ចំណូល ពាណិជ្ជកម្ម និងសកម្មភាពផ្សេងទៀតរបស់ខ្លួន ដែលមានឥទ្ធិពលទៅលើការងារជាតំណាងរាស្ត្រ** (ឧទាហរណ៍៖ សមាជិកក្រុមហ៊ុនពាណិជ្ជកម្ម នាយករោងចក្រកាត់ដេរ ម្ចាស់បនល្បែងកាស៊ីណូ ។ល។) ព្រមទាំងចំនួនទឹកប្រាក់ផ្តល់ជាអំណោយដែលខ្លួនបានទទួល និងពិតណាស់ គឺឈ្មោះរបស់អ្នកផ្តល់អំណោយ ។

# តួនាទីរបស់សមាជិកសភា

## គោលការណ៍សំខាន់ៗ (មាត្រា៧៧ CC):

- សមាជិកសភា តំណាងប្រជាពលរដ្ឋកម្ពុជាទាំងមូល និង
- ពុំមានការចងភ្ជាប់នឹងសេចក្ដីណែនាំ ឬសេចក្ដីបង្គាប់អ្វីនោះទេ ប៉ុន្តែចងភ្ជាប់នឹងមនសិការរបស់ពួកគេ ។

## សិទ្ធិ

- បង្រួបបង្រួម និង បង្កើតក្រុមសភាជាតិ (ក្រុមដែលបង្កើតដោយសមាជិកសភាមួយផ្នែក)
- ផ្លាស់ប្ដូរយោបល់ និងពិភាក្សា និងបញ្ចេញគំនិត
- ទទួលបានអភ័យឯកសិទ្ធិ
- ជាសមាជិកគណៈកម្មការ
- ទទួលបានប្រាក់ខែដូចមន្ត្រីនៃរដ្ឋាភិបាលដែរ

## កាតព្វកិច្ច

- ការចូលរួមយ៉ាងទៀងទាត់នៅក្នុងសម័យប្រជុំរបស់សភា
- គោរពពេលវេលាដែលកំណត់ឱ្យនិយាយ
- ក្នុងពេលតែមួយមិនអាចស្ថិតនៅក្នុងមុខងារ ឬតួនាទីសាធារណៈ (ចែងដោយរដ្ឋធម្មនុញ្ញ) និងជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការជំនាញ របស់សភាជាតិ (វិសមិតភាព)

## ? សំនួរសិក្សាទី ៧

បន្ទាប់ឧប្បត្តិហេតុថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៣ មក ប្រធានគណៈកម្មាធិការកិច្ចការបរទេសនៃរដ្ឋសភា ម្ចាស់ក្សត្រី វិជ្ជរា បានអញ្ជើញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មកបង្ហាញខ្លួននៅសភាជាតិដើម្បីមកធ្វើកសិណសាក្សីអំពីឧបទ្ទវហេតុនេះ ។

ក) តើការកោះអញ្ជើញនេះអាចធ្វើទៅរួចទេ បើយោងទៅតាមរដ្ឋធម្មនុញ្ញ ?
ពុំគ្រាន់តែឆ្លើយថា "អាច" ឬ "មិនអាច" ប៉ុណ្ណោះទេ ប៉ុន្តែបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផងដែរ!

ខ) តើមធ្យោបាយណាផ្សេងដែលម្ចាស់ក្សត្រីអាចប្រើជំនួសការអញ្ជើញ លោកនាយករដ្ឋមន្ត្រីមកបង្ហាញខ្លួននៅសភាជាតិបានទេ ?

គ) តើអ្នកគិតថាហេតុអ្វីបានជាម្ចាស់ក្សត្រីអញ្ជើញ លោកនាយករដ្ឋមន្ត្រី មកបង្ហាញខ្លួននៅសភាជាតិ ហើយមិនអញ្ជើញ រដ្ឋមន្ត្រីក្រសួងការបរទេស ឬរដ្ឋមន្ត្រីដទៃៗទៀត?

## ? សំនួរសិក្សាទី ៨

សមាជិកសភាម្ចាស់ក្សត្រី វិជ្ជរា បាននិយាយនៅពេលសន្និសិទកាសែតឯសភាជាតិថា ម្ចាស់ក្សត្រីបានទទួលព័ត៌មាននាពេលប្រជុំនៅខុទ្ទកាល័យរដ្ឋាភិបាលថា លោកនាយករដ្ឋមន្ត្រីបាននិយាយថា លោកនឹងហៅម្ចាស់ក្សត្រីថា "នាង" ឬ "លោកជំទាវ" នៅពេលខាងមុខ ហើយលោកនឹងដាក់ម្ចាស់ក្សត្រីនៅគុកព្រៃសជាមួយ "ហ្វូងមនុស្ស" ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបដិសេធការចោទប្រកាន់ និងបាននិយាយថា យោបល់របស់ម្ចាស់ក្សត្រី មានបំណងបរិហារ ហើយលោកនឹងរៀបចំបណ្តឹងពីបទបរិហារប្រឆាំងនឹងម្ចាស់ក្សត្រី ។

តើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អាចប្តឹងម្ចាស់ក្សត្រីបានទេ ?

ពុំគ្រាន់តែឆ្លើយថា "អាច" ឬ "មិនអាច" ប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់ហេតុផលចំពោះគំនិតរបស់អ្នក និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផងដែរ!

## ? សំនួរសិក្សាទី ៩

ចូរអានអត្ថបទសង្ខេបដែលដកស្រង់ចេញពីសារព័ត៌មាន The Cambodian Daily ចេញផ្សាយថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០២!

សមាជិកសភាទាំង១៥ មកពីគណបក្ស សមរង្ស៊ី និងសមាជិកសភាមកពីគណបក្ស ហ្វ៊ុនស៊ិនប៉ិចយ៉ាងហោចណាស់ក៏ ១៥នាក់ដែរ ដែលបានធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំសភា បានត្រឡប់ចូលធ្វើការវិញហើយ ដូច្នេះវាផ្តល់លទ្ធភាពឱ្យសភាមានកូរ៉ុមដើម្បីអនុម័តលើច្បាប់ស្តីពីសន្តិសុខសង្គម ។ សមាជិកសភាទាំងអស់នេះ មិនបានទៅសភាចំនួន ៤ថ្ងៃ ពីព្រោះ ពួកគេចង់ធ្វើជាសញ្ញដល់សមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជា ។ ពួកគេបានអះអាងថា សមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជា បានធ្វើពហិការលើការតែងតាំងលោក ខាន់ សាវឿន ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានអនុប្បវាទរបស់សមាជិកសភាមួយចំនួនធំ ដែលធ្វើឱ្យមន្ត្រីរូបនោះមិនអាចទទួលបានសំលេងគាំទ្រ ២/៣ ពីសភា ។

មាត្រាមួយនៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា សម័យប្រជុំរបស់សភាអាចយកជាបានការ នៅពេលដែលចំនួនសមាជិកសភាអប្បបរមាមួយបានចូលរួមប្រជុំ ។

ចូរបញ្ជាក់អំពីមាត្រានេះឱ្យបានច្បាស់លាស់ **និង** ចំនួនសមាជិកសភាប៉ុន្មាននាក់ ដែលត្រូវមានវត្តមាន។

## ? សំនួរសិក្សាទី ១០

សមាជិកសភាអាចអវត្តមាននៅពេលប្រជុំសភាបាន ចំពោះមូលហេតុមួយចំនួនជាកំណត់ប៉ុណ្ណោះ ។

ចូររៀបរាប់អំពីមូលហេតុ**ទាំងអស់**នោះ និងបញ្ជាក់ពីគោលការណ៍ដែលមានចែងនៅបទបញ្ជាផ្ទៃក្នុងនៃសភាជាតិ ។

## ? សំនួរសិក្សាទី ១១

ចូររៀបរាប់អំពីទោសផ្សេងៗចំពោះអវត្តមានមិនត្រឹមត្រូវនៃសមាជិកសភា ។

ចាប់ផ្តើមរាយរាប់ពីទោសស្រាលបំផុតឡើងទៅ និងបញ្ចប់ដោយទោសធ្ងន់បំផុត ("គោលការណ៍នៃភាពសមាមាត្រ") ។

កុំភ្លេចបញ្ជាក់អំពីប្រការនៃបទបញ្ជាផ្ទៃក្នុងរបស់សភាជាតិផង!

## ? សំនួរសិក្សាទី ១២

តំណាងគណបក្សនយោបាយនៅក្នុងសភា មានសិទ្ធិទទួលបាននូវសេរីភាពក្នុងការបង្កើតសមាគម ។

ក) ចូរដកស្រង់នូវបទបញ្ញត្តិជាតិ និងអន្តរជាតិ (មាត្រា) ដែលការពារសេរីភាពក្នុងការបង្កើតសមាគម ។

ខ) តើអ្វីជាភាពខុសគ្នារវាងសេរីភាពខាងការជួបប្រជុំ និងសេរីភាពក្នុងការបង្កើតសមាគម ?

គ) តើអ្វីទៅជាការដាក់កំហិតលើសេរីភាពក្នុងការបង្កើតសមាគម? ចូរដកស្រង់នូវមាត្រាជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធ!